# សេចក្តីថ្លែងការណ៍រួម
# សង្គមស៊ីវិលស្វាគមន៍ចំពោះឱកាសដែលបានជួបជាមួយឯកឧត្តម ស ខេង និងជំរុញឲ្យមានដំណោះស្រាយដោយយុត្តិធម៌លើបញ្ហាជាប់គាំងក្រោយការបោះឆ្នោត

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣

នៅព្រឹកថ្ងៃសុក្រទី៩ ខែសីហា ឆ្នាំ២០១៣ អង្គការសង្គមស៊ីវិលចំនួន១០ ដូចមានរាយនាមខាងក្រោម បានជួបប្រជុំជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង ដើម្បីពិភាក្សាពីដំណើរការបន្តដើម្បីដោះស្រាយបញ្ហាជាប់គាំងផ្នែកនយោបាយដែលបានកើតឡើង បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានប្រារព្ធឡើងនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣កន្លងមក។ អង្គការសង្គមស៊ីវិលបានជំរុញភាគីពាក់ព័ន្ធ រួមទាំងគណបក្សនយោបាយទាំងអស់ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឲ្យៈ

- បន្ធូរបន្ថយភាពតានតឹងនិងពិចារណាលើសារដែលបានបញ្ជូនទៅកាន់ប្រជាពលរដ្ឋកម្ពុជាតាមរយៈការចល័តកងទ័ពរាប់រយនាក់ពីបណ្តាមូលដ្ឋានទ័ពនៅតាមខេត្តមកកាន់រាជធានីភ្នំពេញ
- ការពារសិទ្ធិជួបប្រជុំដោយសន្តិវិធី និងធានាឲ្យមានភាពអត់ធ្មត់ក្នុងកំឡុងពេលបាតុកម្ម ឬការប្រមូលផ្តុំខាងការប្រជុំផ្សេងៗខាងមុខ
- ជៀសវាងឲ្យផុតពីពាក្យសម្តីដែលនាំឲ្យមានការបះបោរ និងការផ្សព្វផ្សាយព័ត៌មានមិនពិតអំពីស្ថានភាពបច្ចុប្បន្ន និងធ្វើការបញ្ជាក់សាជាថ្មីពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះដំណោះស្រាយប្រកបដោយសន្តិវិធី តម្លាភាព និងយុត្តិធម៌
- បង្កើតគណៈកម្មាធិការស៊ើបអង្កេតចម្រុះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីធ្វើការស៊ើបអង្កេតលើពាក្យបណ្តឹងស្តីពីភាពមិនប្រក្រតីក្នុងការបោះឆ្នោត ដែលដាក់បញ្ចូលសមាសភាពអង្គការសង្គមស៊ីវិល អ្នកសង្កេតការណ៍របស់អង្គការសហប្រជាជាតិ និងផ្សព្វផ្សាយជាសាធារណៈពីលទ្ធផលដែលបានរកឃើញ
- ធ្វើរបាយការណ៍ និងផ្សព្វផ្សាយព័ត៌មានស្តីពីការវិវឌ្ឍន៍ និងលទ្ធផលនៃការស៊ើបអង្កេត ក៏ដូចជាការចរចារវាងគណបក្សដែលមានទំនាស់ដោយយុត្តិធម៌ និងតម្លាភាពត្រឹមត្រូវ
- ស្នើមិនឲ្យ គ.ជ.ប ចេញផ្សាយនូវលទ្ធផលផ្លូវការ ដរាបណា ការស៊ើបអង្កេតរបស់គណៈកម្មាធិការចម្រុះកំពុងតែបន្ត
- ធានាថាស្ត្រីត្រូវបានបញ្ចូលនៅក្នុងដំណើរការស៊ើបអង្កេតនោះ រួមទាំងការបង្កើតគណៈកម្មាធិការដោយធានាឲ្យបានថា ដំណើរការនោះជាការឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបង្កើនសមាសភាពរបស់ស្ត្រីជាតំណាងក្នុងវិស័យនយោបាយ ក៏ដូចជាការអនុវត្តន៍ដ៏ល្អបំផុតរបស់អន្តរជាតិដើម្បីឲ្យមានដំណោះស្រាយជម្លោះប្រកបដោយសន្តិវិធី និងកសាងសន្តិភាព ហើយនិង
- បញ្ជូនសេចក្តីបង្គាប់ឲ្យបានច្បាស់លាស់ដល់មេភូមិ ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ទាំងអស់ឲ្យបញ្ឈប់នូវការគំរាមកំហែងដល់ប្រជាពលរដ្ឋនៅក្នុងដែនយុត្តាធិការរបស់ខ្លួន។

អង្គការសង្គមស៊ីវិលសូមស្វាគមន៍ឱកាសដែលអាចចូលរួមពិភាក្សាលើកពីក្តីកង្វល់របស់ខ្លួនជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង ព្រមទាំងធ្វើការជំរុញយ៉ាងមុតមាំដល់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការនេះដើម្បីចូលរួមនៅក្នុងកិច្ចសន្ទនាប្រហាក់ប្រហែលគ្នា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

- លោក អ៊ូ វីរៈ ប្រធាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) តាមរយៈទូរសព្ទ៖+៨៥៥(០)១២ ៤០ ៤០៥១ ឬ អ៊ីម៉ែល៖ ouvirak@cchrcambodia.org ។
- លោកស្រី ពុង ឈីវ កេក ប្រធាន អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) តាមរយៈទូរសព្ទ៖ +៨៥៥ (០) ១២៩០ ២៥០៦ ឬ អ៊ីម៉ែល៖ licadhomail@gmail.com ។
- លោកស្រី ធីតា ឃិះ នាយិកាប្រតិបត្តិ អង្គការសីលការ តាមរយៈទូរសព្ទ៖ + ៨៥៥ (០) ១២៨៣ ៨៤៦៤ ឬ អ៊ីម៉ែល៖ thidaK@silaka.org ។
- លោកស្រី រស់ សុភាព នាយិកាអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (ហ្គេតស៊ី) និងជាអនុប្រធាននៃគណៈកម្មាធិការដឹកនាំនៃគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ(គ.ស.ន) តាមរយៈទូរសព្ទ៖ +៨៥៥ (០) ១២៦២ ៧៨៥៧ ឬ អ៊ីម៉ែល៖ ed@gadc.org.kh ។
- លោក ព្រាប កុល នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា តាមរយៈទូរសព្ទ៖ +៨៥៥ (០) ១២៨៧ ៧៨៣៣ ឬ អ៊ីម៉ែល៖kolpreap@ticambodia.org។